ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

## សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីបិទកិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលថៃ
## នៅខេត្តសៀមរាបថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៤

សូមគោរព ៖

- ឯកឧត្តមPrasarnTrairatvorakulទេសាភិបាលធនាគារកណ្តាលថៃជាទីគោរពរាប់អាន!
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងសមាជិកគណៈប្រតិភូទាំងអស់ជាទីស្នេហា!

កិច្ចប្រជុំទ្វេភាគីរបស់យើងបានឈានដល់ទីបញ្ចប់ហើយ បន្ទាប់ពីគណៈប្រតិភូធនាគារកណ្តាលទាំងពីរបានប្រជុំពិភាក្សាផ្លាស់ប្តូរយោបល់គ្នាអំពីព័ត៌មានសេដ្ឋកិច្ច បទពិសោធន៍ក្នុងការដឹកនាំនយោបាយរូបិយវត្ថុ ការគ្រប់គ្រងធនាគារកណ្តាល ការត្រួតពិនិត្យធនាគារ និងការពង្រឹងកិច្ចសហប្រតិបត្តិការលើផ្នែកបណ្តុះបណ្តាលធនធានមនុស្ស ។ ខ្ញុំសូមវាយតម្លៃខ្ពស់ថាកិច្ចប្រជុំរបស់យើងបានប្រព្រឹត្តទៅយ៉ាងសកម្ម និងប្រកបដោយជោគជ័យ ។

កិច្ចប្រជុំនេះ គឺមានសារៈសំខាន់ណាស់ព្រោះជាវេទិកាសម្រាប់ឱ្យមន្ត្រីបុគ្គលិករបស់ធនាគារកណ្តាលនៃប្រទេសទាំងពីរ ផ្លាស់ប្តូរព័ត៌មាននិងបទពិសោធន៍ ព្រមទាំងផ្តល់ឱកាសឱ្យមន្ត្រីបច្ចេកទេសក្នុងវិស័យធនាគារ ពង្រឹងកិច្ចសហប្រតិបត្តិការប្រកបដោយស្មារតីសាមគ្គីភាពនិងភាតរភាពផង។

ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម ទេសាភិបាល ផ្ទាល់ ចំពោះការយកចិត្តទុកដាក់របស់ ឯកឧត្តម ក្នុងការបង្កើនចំណងមិត្តភាពជិតស្និទ្ធរវាងស្ថាប័នទាំងពីរ ហើយខ្ញុំសង្ឃឹមថា មន្ត្រីបុគ្គលិករបស់យើងយកស្មារតីនៃកិច្ចប្រជុំថ្ងៃនេះប្រែក្លាយទៅជាការអនុវត្តជាក់ស្តែង ក្នុងគោលបំណងពង្រឹងនិងពង្រីកចំណងកិច្ចសហប្រតិបត្តិការមិត្តភាព រួមចំណែកអភិវឌ្ឍវិស័យធនាគារ សេដ្ឋកិច្ច ដើម្បីបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋនៃប្រទេសយើងទាំងពីរ ។

ជាទីបញ្ចប់ខ្ញុំសូមគោរពជូនពរដល់ឯកឧត្តមនិងគណៈប្រតិភូទាំងអស់ សូមមានសុខភាពល្អ និងទទួលបានជ័យជម្នះ គ្រប់ភារកិច្ចនិងសូមជូនពរដល់ធនាគារកណ្តាលថៃទទួលបាននូវជោគជ័យថ្មីៗបន្ថែមទៀត ។

**សូមអរគុណ**

ប្រអប់សំបុត្រលេខ ២៥, ល្វែងលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧